


និពន្ធដោយ TukTuk

រូបភាពដោយ Hen Choven



ថ្ងៃមួយ យ៉េកនិងខេទីបានជិះរត់នានិងមកភាទៅភូមិស្វាយចេក
ទាំងពេលនោះមេឃកំពុងរលឹមព្រិចៗ។



នៅតាមផ្លូវ ពួកគេបានជិះកាត់រ៉ឺម៉កកង់បីជាច្រើន។



តើរ៉ឺម៉កកង់បីទាំងនោះមានពណ៌អ្វី?

ត្រូវហើយ! រ៉ឺម៉កកង់បីភាគច្រើនមានពណ៌ក្រហម។



បន្តិចក្រោយមក ពួកគេបានជិះកាត់លោកសង្ឃកំពុងនិមន្តតាមផ្លូវ ដោយក្នុងព្រះហស្តកាន់ឆ័ត្រស្អាតៗគ្រប់ព្រះអង្គ។



តើលោកសង្ឃគ្រងស្បង់ពណ៌អ្វីដែរ?

ត្រូវហើយ! ទ្រង់គ្រងស្បង់ពណ៌ទឹកក្រូច។



ពួកគេបានជិះកាត់ដើមស្វាយដ៏ធំត្រឈឹងត្រឈៃមួយដែលមានផ្លែជាច្រើន។
តើផ្លែស្វាយមានពណ៌អ្វី?



ពេលដែលវាទុំហើយផ្អែម វាមានពណ៌លឿង។
តែតនានិងមករាប្រែជាចូលចិត្តញុំាស្វាយពេលវានៅពណ៌បៃតងទៅវិញ។



ពួកគេបានជិះបត់តាមផ្លូវកោង ហើយមេឃក៏ចាប់ផ្ដើមរាំង។



តើមេឃមានពណ៌អ្វី?

ត្រូវហើយ! មេឃមានពណ៌ខៀវដូចរ៉ឺម៉កកង់បីរបស់យ៉េកអ៊ីចឹង។



ពួកគាត់បានជិះកាត់វាលមួយពោរពេញទៅដោយផ្កាអមតៈ។

នៅពេលយើងយកផ្កាអមតៈឆុងជាទឹកតែ តើវាចេញពណ៌អ្វី?



ទឹកតែនោះនឹងចេញពណ៌ខៀវស្វាយស្អាតណាស់។

ចុះពេលយើងដាក់ក្រូចឆ្មារចូលទៅ តើវាចេញពណ៌អ្វី? វានឹងចេញពណ៌ស្វាយ។





មករាលើកដៃចង្អុលហើយស្រែក « មើលនោះទៅ! មានកេលាបពណ៌លើមេឃន៎! »
ដោយមានឥន្ទធនូមួយបានបង្ហាញខ្លួននៅលើមេឃ។



រតនាក៏បាននិយាយ « នែ មករា! កុំចង្អុលទៅឥន្ទធនូអីចឹង ប្រយ័ត្នដាច់ម្រាមដៃទៅណា »។ មករាភ័យក៏ទម្លាក់ដៃរបស់ខ្លួនចុះភ្លាម។



ខេទីសួរ « ហេតុអ្វីទៅ? »

រតនាឆ្លើយ « ម្ដាយខ្ញុំតែងប្រាប់ថា បើយើងចង្អុលទៅផ្គរលាន់ យើងនឹងដាច់ម្រាមដៃជាមិនខាន »។



មករាក៏និយាយ « តែឥន្ទធនូស្អាតខ្លាំងណាស់។
បើសិនខ្ញុំអាចលាបពណ៌ឱ្យមេឃដូចអ៊ីចឹងដែរ មិនដឹងជាសប្បាយប៉ុណ្ណាទេ »។



យ៉េកញ្ញខេទីនិយាយជាមួយក្មេងៗដូចនេះ

គាត់ក៏បានឈប់រ៉ឺម៉កកង់បីបន្តិច ដើម្បីមើលឥន្ទធនូទាំងអស់គ្នា



ហើយយ៉េកក៏ចាប់ផ្ដើមនិយាយបកស្រាយពីឥន្ទធនូ។




គាត់ចាប់ផ្ដើមបកស្រាយ « ឥន្ទធនូមើលទៅដូចជាកេលាបពណ៌លើមេឃអីចឹង តែតាមពិតវាគ្រាន់តែជាពន្លឺនៅលើមេឃប៉ុណ្ណោះ »។




គាត់បន្តទៀត « ទឹកភ្លៀងនិងពន្លឺថ្ងៃបូកចូលគ្នាបង្កើតបានជាពណ៌ដ៏ស្រស់ស្អាតទាំងនេះ »។
មករាក៏តប « ស្តាប់ទៅដូចមានផទមន្តលើមេឃអ៊ីចឹង »។



យ៉េកក៏សួរក្មេងៗ « តើអ្នកទាំងពីរស្គាល់ពណ៌ទាំងអស់ក្នុងឥន្ទធនូដែរឬទេ? »



រតនានិងមករាងើយមើលទៅមេឃ ហើយក៏ចាប់ផ្ដើមរាប់ « ពណ៌ក្រហម ពណ៌ទឹកក្រូច ពណ៌លឿង ពណ៌បៃតង ពណ៌ខៀវ ហើយពណ៌... »



ខេទីបឆ្លើប « នៅមានពីរពណ៌ទៀតណា! »

យ៉េកក៏ឆ្លើយ « ត្រូវហើយ! នៅមានពណ៌ខៀវស្វាយនិងពណ៌ស្វាយទៀត »។



ខេទីក៏បានបន្តប្រាប់ពួកគេ « នៅប្រទេសអូស្រ្តាលី គេមានជំនឿតៗគ្នាថា
ប្រសិនបើយើងធ្វើដំណើរដល់ចុងឥន្ទធនូ នោះបំណងប្រាថ្នារបស់យើងនឹងក្លាយជាការពិត »។



ក្មេងៗក៏សួរទៅ ខេទីភ្លាម « ពិតមែនឬ? ចុះអ្នកធ្លាប់ទៅដល់ចុងឥន្ទធនូទេ? »



ខេទីក៏ឆ្លើយ « ខ្ញុំធ្លាប់ខំសាកទៅប៉ុន្មានដងដែរ តែវាល់ដងឱ្យតែមុនពេលខ្ញុំទៅដល់ចុងឥន្ទធនូនោះ វាតែងបាត់ខ្លួនជានិច្ច។



នៅពេលយើងធ្វើដំណើរ ឥន្ទធនូហាក់បីដូចជាធ្វើដំណើរតាមយើងអីចឹងដែរ។
ឥឡូវ នៅពេលខ្ញុំឃើញវា ខ្ញុំមិនដើរតាមវាទៀតទេ តែខ្ញុំចូលចិត្តអង្គុយមើលពណ៌របស់វាទៅវិញ »។





« តែខ្ញុំនៅតែចូលចិត្តប្រាប់បំណងប្រាថ្នារបស់ខ្ញុំទៅឥន្ទធនូអីចឹង... »





ដូច្នេះពួកគេទាំងបួននាក់ក៏នៅមើលឥន្ទធនូរហូតដល់វាបាត់ខ្លួន
ហើយពួកគេក៏បានប៉ងប្រាថ្នាក្នុងចិត្តប្រាប់ទៅឥន្ទធនូផងដែរ។


ចប់ដោយបរិបូរណ៍

អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C

អង្គការរ៉ឺម៉កកង់បីសម្រាប់កុមារ(R4C)គឺជាអង្គការដែលមិនរកប្រាក់ចំណេញនិងផ្តោតលើការអប់រំកុមារតូចក្នុងប្រទេសកម្ពុជា។

អង្គការR4Cកំពុងដំណើរការគម្រោងកម្មវិធីបណ្ណាល័យចល័តតាមប្រព័ន្ធអនឡាញ ដែលមាននិន្នាការទៅលើសាលាមត្តេយ្យរដ្ឋនិងមត្តេយ្យសហគមន៍។

អង្គការR4Cបានចូលរួមអភិវឌ្ឍន៍ធនធានដ៏សមស្របទៅនឹងកម្មវិធីសិក្សារបស់ក្រសួងនិងមានវគ្គបំប៉នលោកគ្រូ អ្នកគ្រូ។
សូមចូលទៅកាន់គេហទំព័រ ដើម្បីទទួលបានធនធានបន្ថែម៖ https://rermork.org/

ទទួលបានព័ត៌មានបន្ថែម

TUKTUK

Rotary

មូលនិធិផ្តល់ដោយអង្គការ TuTukនិងសមាគមរ៉ូតារីក្លឹប។

សៀវភៅរឿងនេះគឺនិពន្ធដោយ Robert McCurdy និងRoberta Dahl ជាអ្នកស្ម័គ្រចិត្តដោយក្តីមេត្តាធម៌។ ពួកយើងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់អ្នកស្ម័គ្រចិត្តនិងបុគ្គលិកទាំងអស់នៅក្នុងអង្គការជាមួយនឹង Sally Heinrich ដែលបានចូលរួមកែសម្រួលនិងបកប្រែសៀវភៅរឿងនេះ។

ទទួលបានគំនូរជីវចល

ទទួលបានធនធានបន្ថែម